រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ៥

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មរស់ឡើងវិញ សង្គ្រោះយើង ដោយសារជំនឿរបស់យើង

មានថ្ងៃមួយ ពេលយើងធ្វើដំណើរទៅកន្លែងអធិស្ឋាន មានស្រីបំរើគេម្នាក់មកជួបយើង នាងមានខ្មោចឈ្មោះពិថុនចូល នាំអោយនាងចេះទាយធ្វើឱ្យពួកម្ចាស់របស់នាងបានទទួលកំរៃយ៉ាងច្រើន ។ នាងដើរតាមក្រោយលោកប៉ូល និងយើងទាំងស្រែកថា÷ «លោកទាំងនេះ ជាអ្នកបំរើរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត លោកនាំដំណឹងអំពីមាគ៌ាមួយនៃការសង្គ្រោះមកប្រាប់អ្នករាល់គ្នា » ។

នាងធ្វើបែបនេះ អស់រយៈពេលជាច្រើនថ្ងៃ ។ ដោយលោកប៉ូលទាស់ចិត្តជាខ្លាំង ក៏ងាកទៅក្រោយបញ្ជាខ្មោចថា÷ «ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ចូរចេញពីនាងទៅ !» ខ្មោចក៏ចេញពីនាងភ្លាម ។

កាលពួកម្ចាស់របស់ស្រីបំរើនោះឃើញថាលែងមានសង្ឃឹមនឹងបានកំរៃអ្វីទៀត គេក៏នាំគ្នាចាប់លោកប៉ូល និងលោកស៊ីឡាសអូសយកទៅជូនចៅក្រមនៅលានសាធារណៈក្នុងទីក្រុង ។ ចៅក្រមនាំលោកទាំងពីរទៅជួបពួកអាជ្ញាធរ ពោលថា÷ «ជនជាតិយូដាទាំងនេះ បង្កអោយមានចលាចលនៅក្នុងក្រុងយើង ។ គេនាំទំនៀមទម្លាប់ផ្សេងៗមកផ្សាយប្រាប់យើង ជាទំនៀមទម្លាប់ ដែលយើងជនជាតិរ៉ូម៉ាំងគ្មានសិទ្ធិនឹងទទួល ឬ អនុវត្តតាមបានឡើយ » ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

បណ្ដាជនក៏លើកគ្នាមកប្រឆាំងនឹងលោកទាំងពីរដែរ ។ ពួកអាជ្ញាធរបានបញ្ជាអោយគេដោះសម្លៀកបំពាក់លោកប៉ូល និងលោកស៊ីឡាសចេញ រួចបញ្ជាអោយវាយនឹងរំពាត់ ។ ក្រោយពីបានវាយលោកទាំងពីរច្រើនរំពាត់ហើយ គេក៏យកលោកទៅដាក់ក្នុងទីឃុំឃាំង ទាំងបញ្ជាអោយយាមយ៉ាងមធ្យឹតផង ។ ឆ្នាំគុកក៏យកលោកទាំងពីរទៅឃុំក្នុងគុកងងឹត និងដាក់ខ្នោះជើងតាមបញ្ជាដែលគាត់បានទទួល ។

ប្រមាណជាពាក់កណ្ដាលអាធ្រាត្រ លោកប៉ូល និងលោកស៊ីឡាសនាំគ្នាអធិស្ឋាន និងច្រៀងសរសើរតម្កើងព្រះជាម្ចាស់ ។ អ្នកទោសឯទៀតៗស្ដាប់លោកទាំងពីរ ។ រំពេចនោះ ស្រាប់តែមានរញ្ជួយផែនដីយ៉ាងខ្លាំង បណ្ដាលឱ្យកក្រើកដល់គ្រឹះទីឃុំឃាំង ។

ទ្វារគុកទាំងប៉ុន្មាន ក៏របើកឡើងភ្លាម រីឯច្រវាក់ដែលគេដាក់អ្នកទោស ក៏របូតចេញអស់ដែរ ។ ពេលនោះ ឆ្នាំគុកភ្ញាក់ឡើង លុះគាត់ឃើញទ្វារគុករបើកដូច្នេះ គាត់ក៏ហួតដាវបំរុងនឹងសម្លាប់ខ្លួនព្រោះនឹកស្មានថា អ្នកទោសរត់បាត់អស់ហើយ ។ ប៉ុន្តែ លោកប៉ូលបានស្រែកឡើងយ៉ាងខ្លាំងៗថា÷ «កុំធ្វើបាបខ្លួនអី យើងទាំងអស់គ្នានៅឯនេះទេ ! » ។

ឆ្នាំគុកសុំអោយគេយកភ្លើងមក រួចប្រញាប់ប្រញាល់ចូលទៅក្នុងគុក ។ គាត់ក្រាបចុះនៅមុខលោកប៉ូល និងលោកស៊ីឡាសទាំងញាប់ញ័រ ។

គាត់នាំលោកទាំងពីរចេញមកក្រៅ ពោលថា÷ «លោកម្ចាស់ ! តើខ្ញុំប្របាទត្រូវធ្វើយ៉ាងណា ដើម្បីឱ្យបានទទួលការសង្គ្រោះ ?»។ លោកតបទៅគាត់វិញថា÷ «សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោក ព្រមទាំងសង្គ្រោះក្រុមគ្រួសាររបស់លោកផងដែរ » ។

បន្ទាប់មក លោកទាំងពីរបានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់គាត់ និងប្រាប់អ្នកទាំងប៉ុន្មានដែលនៅក្នុងផ្ទះគាត់ ។ ពេលនោះឆ្នាំគុក នាំលោកទាំងពីរមកលាងស្នាមរបួសទាំងយប់ ហើយគាត់ និងក្រុមគ្រួសាររបស់គាត់ ក៏បានទទួលពិធីជ្រមុជទឹកភ្លាម ។ គាត់បាននាំលោកទាំងពីរឡើងទៅផ្ទះគាត់ រៀបចំម្ហូបអាហារជូន។ គាត់ និងក្រុមគ្រួសាររបស់គាត់មានអំណរសប្បាយ ដោយបានជឿលើព្រះជាម្ចាស់ ។ (កិច្ចការ ១៦:១៦-៣៤) ។

សាវ័កប៉ូលដេញខ្មោចចេញពីនារីបំរើនោះ ។ តើលោកប៉ូលដេញខ្មោចក្នុងនាមនរណា ?

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ទូលសូមឱ្យព្រះជាម្ចាស់ ប្រទានការសង្គ្រោះដ៏នៅអស់កល្ប តាមរយៈព្រះយេស៊ូដល់អ្នក (ការនេះមិនមែនកើតមាន ដោយសារអំពើល្អ ដែលអ្នកបានធ្វើនោះទេ តែដោយសារ តែអ្វីៗ ដែលព្រះគ្រីស្តបានធ្វើ ដោយសុគត ដើម្បីយើង និង មានព្រះជន្មរស់ឡើងវិញ) ។
- ពន្យល់រឿងអំពីឆ្នាំគុកប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

ហេតុអ្វីបានជាគេចាប់លោកប៉ូល និងលោកស៊ីឡាសទៅដាក់ក្នុង មន្ទីរឃុំឃាំង ?

_____

_____

តើលោកប៉ូល និងលោកស៊ីឡាសបានធ្វើអ្វីខ្លះ នៅពេលជាប់នៅ ក្នុងមន្ទីរឃុំឃាំង ?

_____

_____

ហេតុអ្វីបានជាច្រវាក់ដែលគេដាក់ពួកអ្នកទោស ត្រូវរបូតចេញ ?

_____

តើឆ្នាំគុកប្រុងធ្វើអ្វីចំពោះខ្លួនគាត់ ?

_____

ក្រោយដែលបានដោះលែងលោកប៉ូល និងលោកស៊ីឡាសពីគុក ហើយ តើឆ្នាំគុកសួរលោកប៉ូល និង លោកស៊ីឡាសថាដូចម្តេច ?

_____

© Project WorldReach © SEAN

តើលោកប៉ូល និងលោកស៊ីឡាសប្រាប់ឆ្នាំគុកថា ត្រូវធ្វើអ្វី ដើម្បីអោយបានសង្គ្រោះ ?

ក្រោយដែលបានលាងស្នាមរបួសរបស់លោកប៉ូល និងលោកស៊ីឡាសហើយ តើឆ្នាំគុក និងគ្រួសាររបស់គាត់ធ្វើអ្វី ?

តើព្រះយេស៊ូធ្វើដូចម្តេច ដើម្បីសង្គ្រោះយើង ?

តើនៅថ្ងៃទីបី (បន្ទាប់ពីគេឆ្កាងព្រះអង្គមក) ព្រះយេស៊ូធ្វើអ្វី ?

តើអ្នកជឿថា ការសុគតរបស់ព្រះយេស៊ូគ្រីស្តលួមគ្រប់គ្រាន់ ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់អ្នក និងគ្រួសាររបស់អ្នកដែរឬទេ ?

☐ លួមគ្រប់គ្រាន់ ។

☐ មិនលួមគ្រប់គ្រាន់ទេ ។

តើអ្នកជឿថា ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត អាចផ្តល់ជីវិតថ្មីដល់អ្នក និងគ្រួសាររបស់អ្នកដែរឬទេ ?

☐ អាចផ្តល់ជីវិតថ្មី ។

☐ មិនអាចផ្តល់ជីវិតថ្មីទេ ។

ព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ចង់ប្រទានជីវិតថ្មីដល់អ្នក ។ តើជីវិតថ្មីនេះ មានរយៈពេលប៉ុន្មាន ?

ខ សំរាប់ទន្ទេញ

«អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿ នឹងត្រូវទទួលទោស » ។

(ម៉ាកុស ១៦:១៦)